ព្រះរាជាណាចក្រកម្ពុជា

ជាតិ | សាសនា | ព្រះមហាក្សត្រ

# ចក្ខុវិស័យកម្ពុជា

## ២០៣០ & ២០៥០

**ផែនទីបង្ហាញផ្លូវ វ.ប.ន.កម្ពុជា ២០៣០**

អភិបាលកិច្ច | ការអប់រំ | ការស្រាវជ្រាវ | កិច្ចសហការ | ប្រព័ន្ធអេកូឡូស៊ី

**ផែនទីបង្ហាញផ្លូវ វ.ប.ន.កម្ពុជា ២០៣០ នេះត្រូវបានកសាង ដោយផ្អែកលើគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិផ្សេងៗ**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

# គោលដៅ

**វ.ប.ន.** ជាកម្លាំងចលករ និងជាក្បាលម៉ាស៊ីនយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមដោយពន្លឿនការធ្វើបរិវត្តកម្មរចនាសម្ព័ន្ធពីការអភិវឌ្ឍសេដ្ឋកិច្ចអតិពលកម្មទៅជាសេដ្ឋកិច្ចពឹងផ្អែកលើចំណេះដឹង។ **ផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០** ជាឯកសារគោលនយោបាយយុទ្ធសាស្ត្រដ៏មានសារៈសំខាន់ដើម្បីជួយតម្រង់ទិសក្រសួង-ស្ថាប័ន និងតួអង្គពាក់ព័ន្ធសំខាន់ៗក្នុងប្រព័ន្ធនវានុវត្តន៍ជាតិ អនុវត្តន៍ផែនការសកម្មភាពក្រោមកិច្ចសម្របសម្រួលពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**ក.ឧ.វ.ប.ន.**) និងការបង្ហាញផ្លូវពីក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**ក.ជ.វ.ប.ន.**) ដើម្បីសម្រេចគោលដៅដែលបានកំណត់តាមពេលវេលាជាក់លាក់មួយ។

# សេចក្តីផ្តើម

**ផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០** ផ្តោតលើសសរស្តម្ភ ៥៖ អភិបាលកិច្ច ការអប់រំ ការស្រាវជ្រាវ កិច្ចសហការ និងប្រព័ន្ធអេកូឡូស៊ី។ គោលដៅ គោលនយោបាយ និងសកម្មភាពជាក់លាក់ដោយមានលិខិតូបករណ៍ និងសូចនាករដែលអាចវាស់វែងបានតាមពេលវេលាជាក់លាក់មួយត្រូវបានស្នើឡើងសម្រាប់តួអង្គពាក់ព័ន្ធអនុវត្តន៍។ ដូច្នេះ ផែនទីបង្ហាញផ្លូវនេះគឺជាសម្បត្តិដ៏មានសារៈសំខាន់ក្នុងការសម្រេចចក្ខុវិស័យឆ្នាំ២០៣០&២០៥០។

## អភិបាលកិច្ច

**ពង្រឹងអភិបាលកិច្ចនៃប្រព័ន្ធ វ.ប.ន.**

- **ក.ឧ.វ.ប.ន.** ដឹកនាំសម្របសម្រួលគោលនយោបាយ **វ.ប.ន.** ក្រោមការណែនាំពី **ក.ជ.វ.ប.ន.**
- ១% នៃ **ផ.ស.ស.** ត្រូវវិនិយោគលើ **វ.ប.ន.** ដែលពាក់កណ្តាលបានមកពីរដ្ឋត្រឹមឆ្នាំ ២០៣០
- វឌ្ឍនភាពនៃការផ្តល់មូលនិធិសាធារណៈផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ត្រឹមឆ្នាំ ២០៣០

## ការអប់រំ

**កសាងមូលធនមនុស្សក្នុងវិស័យ វ.ប.ន.**

- ៥០% និស្សិតបញ្ចប់ការសិក្សាផ្នែកស្ទែម ត្រឹមឆ្នាំ ២០៣០
- កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតត្រូវបានបង្កើតឡើងជាមួយវិស័យឯកជន មុនឆ្នាំ២០២៤
- វេទិកាបច្ចេកវិទ្យាត្រូវបានបង្កើតឡើងនៅតាមសាកលវិទ្យាល័យ និង គ្រឹះស្ថានជីវេត ត្រឹមឆ្នាំ ២០២៣
- សារមន្ទីរវិទ្យាសាស្ត្រចំនួន២ត្រូវបានបង្កើត ត្រឹមឆ្នាំ២០៣០ ក្នុងនោះ១ នៅភ្នំពេញ ត្រឹមឆ្នាំ ២០២៣
- ព្រឹត្តិការណ៍នវានុវត្តន៍ចំនួន ២០ ឬវេទិកានវានុវត្តន៍ចំនួន ២០ ត្រឹម២០៣០
- បណ្ណាល័យវិទ្យាសាស្ត្រចំនួន៣ ត្រូវបានបង្កើត ត្រឹមឆ្នាំ ២០៣០ ក្នុងនោះ ១ នៅរាជធានីភ្នំពេញត្រឹមឆ្នាំ ២០២៣

## ការស្រាវជ្រាវ

**ពង្រឹងសមត្ថភាព និងគុណភាពនៃការស្រាវជ្រាវ**

- របៀបវារៈស្រាវជ្រាវជាតិរយៈពេល៥ឆ្នាំត្រូវបានបង្កើតដើម្បីកំណត់ទិសដៅសម្រាប់ការស្រាវជ្រាវ
- មូលនិធិស្រាវជ្រាវត្រូវបានបង្កើតឡើងត្រឹមឆ្នាំ២០២៣
- ១% នៃ **ផ.ស.ស.** ត្រូវបានវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រឹមឆ្នាំ ២០៣០
- អត្ថបទបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តីអន្តរជាតិចំនួន១៥០០ ដោយអ្នកវិទ្យាសាស្ត្រខ្មែរត្រូវសម្រេចបានត្រឹមឆ្នាំ២០៣០
- សាកលវិទ្យាល័យស្រាវជ្រាវ/មជ្ឈមណ្ឌលស្រាវជ្រាវឆ្នើមចំនួន៧ ត្រូវបានរៀបចំឡើង ត្រឹមឆ្នាំ ២០២៥

## កិច្ចសហការ

**បង្កើនកិច្ចសហការ និងបង្កើតបណ្តាញរវាងភាគីពាក់ព័ន្ធវ.ប.ន.**

- សាកលវិទ្យាល័យចំនួន៥ បង្កើតការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងសហគ្រាស ត្រឹមឆ្នាំ២០២៣ និង៥០% នៃសាកលវិទ្យាល័យទូទាំងប្រទេស ត្រឹមឆ្នាំ ២០៣០
- កម្មសិក្សានៅក្នុងរោងចក្រសហគ្រាសត្រូវបានបញ្ចូលនៅក្នុងកម្មវិធីសិក្សា ត្រឹមឆ្នាំ ២០៣០
- គោលនយោបាយសួនឬបណ្តុំ **វ.ប.ន.** ត្រូវបានអនុម័តត្រឹមឆ្នាំ២០២២ ដែល ៣ នឹងដាក់ឱ្យសាកល្បងត្រឹមឆ្នាំ២០២៣ និងដំណើរការពេញលេញ ត្រឹមឆ្នាំ ២០២៥

## ប្រព័ន្ធអេកូឡូស៊ី

**ជំរុញឱ្យមានប្រព័ន្ធអេកូឡូស៊ីដ៏សមស្របសម្រាប់ការវិនិយោគនៅក្នុងវិស័យ វ.ប.ន.**

- ច្បាប់ផ្ទេរបច្ចេកវិទ្យា និងយន្តការត្រូវបានបង្កើតនឹងដាក់ឱ្យប្រើប្រាស់ពេញលេញត្រឹមឆ្នាំ២០២៣
- របបកម្មសិទ្ធិបញ្ញាត្រូវបានពង្រឹងដោយមានយន្តការសមស្របត្រឹមឆ្នាំ ២០២៣
- ពិន្ទុខ្ពស់ជាងកម្រិតមធ្យមនៅអាស៊ាន លើសន្ទស្សន៍នវានុវត្តន៍សកល ត្រឹមឆ្នាំ ២០៣០

រក្សាសិទ្ធដោយ ក្រសួង ឧ.វ.ប.ន.
ឆ្នាំ២០២១